ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តព្រះវិហារ

លេខ ២៣៨ សជណ/គអ/ទផវិ

ព្រះវិហារ,ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៥

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦**

សាលាខេត្តព្រះវិហារ សូមជម្រាបជូនដល់អ្នកទទួលការទាំងអស់ឲ្យបានជ្រាបថា អាជ្ញាធរខេត្តនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦ ដើម្បីដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ ដោយចាប់ផ្តើមទទួលពាក្យសុំចុះឈ្មោះអ្នកទទួលការ ឬដាក់ពាក្យជាថ្មីឡើងវិញ គិតចាប់ថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ៥:៣០នាទីល្ងាច។ អ្នកទទួលការ ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅគ្រប់ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជាបីប្រភេទ៖

- ប្រភេទទី១៖ អ្នកទទួលការសំណង់ទូទៅ(ការងារសំណង់អគារ និងការងារបេតុ ...។ល។)
- ប្រភេទទី២៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រាលក្រួសក្រហម ...។ល។)
- ប្រភេទទី៣៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនិងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ក្នុងអំឡុងពេល ៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនអ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះអនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច។ អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធជាផ្លូវការ អ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យនៅទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត តាមកាលបរិច្ឆេទដែលបានកំណត់ខាងលើ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យជាថ្មីឡើងវិញដែរ ដោយមកយកពាក្យសុំចុះឈ្មោះ នៅទីចាត់ការផែនការ និងវិនិយោគដែលមានទីតាំងនៅក្នុងបរិវេណសាលាខេត្តព្រះវិហារ ដោយឥតបង់ថ្លៃ ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប (www.ncdd.gov.kh)។/៚

ត.ប.គណៈអភិបាលខេត្ត

នាយករដ្ឋបាល

សុខ_ហៃ

-ឯកសារ-កាលប្បវត្តិ